ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈទន្តពេទ្យកម្ពុជា

# បទដ្ឋាននៃការអនុវត្តផ្នែកទន្តសាស្ត្រនៅក្នុងបណ្តាប្រទេសតំបន់អាស៊ាន
# ASEAN Dental Practice Standards

| **បទដ្ឋាននៃការអនុវត្ត**<br>**Statement of Practice Standard** | **វិសាលភាពនៃសមត្ថភាពអនុវត្តការងារ**<br>**Scope of Performing Abilities** |
|---|---|
| 1. ការអនុវត្តក្នុងគ្លីនិក ត្រូវតែផ្សាភ្ជាប់ទៅនឹងសុវត្ថិភាពរបស់អ្នកជំងឺ ការអនុវត្តបែបសម័យទំនើបនិង បទដ្ឋានវិជ្ជាជីវៈ<br><br>Clinical practice must encapsulate patient safety, contemporary practice, and professional standards | • អ្នកវិជ្ជាជីវៈទន្តសាស្ត្រទាំងអស់ ជានិច្ចកាលត្រូវយល់ដឹងពីគោលការណ៍អនុវត្ត និងការទទួលខុសត្រូវលើ ក្រមសីលធម៌វិជ្ជាជីវៈ<br>Dental professionals should always understand and apply principles of ethical practice and professional responsibility<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវធានាថា ការប្រត្តិបត្តិវិជ្ជាជីវៈទន្តសាស្ត្ររបស់ខ្លួនរក្សាបាននូវទំនុកចិត្តពីអ្នកជំងឺ និងសាធារណៈជន<br>Dental practitioners should ensure that their personal conduct maintains the patients' and public's trust in the dental profession<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវមានទំនាក់ទំនងល្អជាសហភាគរ: ភាពស្និទ្ធស្នាល និងប្រតិបត្តការងារដោយប្រសិទ្ធិភាព ក្នុងផលប្រយោជន៍របស់អ្នកជំងឺ<br>Dental practitioners should communicate clearly and work effectively and cordially with colleagues in the interest of patients |
| 2. ការគ្រប់គ្រងអ្នកជម្ងឺ ត្រូវតែមានការយកចិត្តទុកដាក់ ដោយផ្តោតអារម្មណ៍ទូលំទូលាយ និទទួលការយល់ព្រមពីអ្នកជំងឺ<br><br>Patient management must be patient-centric, comprehensive and with informed consent | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវមានការប្រាស្រ័យទាក់ទងច្បាស់ជាមួយអ្នកជំងឺ<br>Dental practitioners should communicate effectively with patients<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវផ្តល់ព័ត៌មានច្បាស់លាស់ដល់អ្នកជំងឺ ស្តីពីជម្រើសនានា លទ្ធផល និងតម្លៃនៃការព្យាបាល<br>Dental practitioners should provide patients with clear information about all relevant treatment options, outcomes and possible costs |

| បទដ្ឋាននៃការអនុវត្ត<br>**Statement of Practice Standard** | វិសាលភាពនៃសមត្ថភាពអនុវត្តការងារ<br>**Scope of Performing Abilities** |
|---|---|
| | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវទទួលស្គាល់ និងគាំទ្រសិទ្ធិរបស់អ្នកជំងឺ ក្នុងការសម្រេចចិត្ត អំពីសុខភាព និងការថែទាំសុខភាព ដែលពួកគាត់បានទទួល<br>Dental practitioners should acknowledge and support patients' rights to make decisions about their health and care they receive<br><br>• អ្នកវិជ្ជាជីវៈទន្តសាស្ត្រទាំងអស់ ត្រូវទទួលបានការយល់ព្រមពីអ្នកជំងឺមុននឹងចាប់ផ្តើមព្យាបាល<br>Dental professionals should obtain valid and informed consent from patients before starting treatment.<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវពិនិត្យ និងព្យាបាលជំងឺ ប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរពគ្រប់កាលទេសៈ និងគ្រប់គ្រងអ្នកជំងឺ និងសហភាតរៈដោយគ្មានការរើសអើង<br>Dental practitioners should treat patients with dignity and respect at all times, and manage patients and colleagues from diverse backgrounds and beliefs without prejudice or discrimination<br><br>• អ្នកវិជ្ជាជីវៈទន្តសាស្ត្រទាំងអស់ ត្រូវទុកនូវផលប្រយោជន៍អ្នកជំងឺជាអាទិភាព<br>Dental professionals should put patients' interests first |
| 3. អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ដែលប្រត្តិបត្តក្នុងបន្ទប់ពិគ្រោះ ព្យាបាលជំងឺ ត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ ចុះឈ្មោះក្នុងគណៈវិជ្ជាជីវៈ និង/ឬ មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ<br><br>All dental practitioners in a clinic must be appropriately qualified and must be registered and/or licensed | • អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រទាំងអស់ ត្រូវតែមានគុណវឌ្ឍិ ដែលទទួលស្គាល់ និងផ្តល់អាជ្ញាបណ្ណដោយស្ថាប័នបទប្បញ្ញត្តិក្នុងប្រទេស<br>All dental practitioners must have qualifications that are recognised and licensed by the country's regulatory body<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវតែយល់ដឹង និងអនុវត្តតាមច្បាប់ បទដ្ឋានគតិយុត្តទាំងឡាយ ទាក់ទងនឹងការផ្តល់សេវាសុខភាពមាត់-ធ្មេញ ដែលតម្រូវដោយស្ថាប័នបទប្បញ្ញត្តិក្នុងប្រទេស<br>Dental practitioners should be aware of, and comply with all legal and regulatory requirements related to the provision of oral health care of the country's regulatory body |

| បទដ្ឋាននៃការអនុវត្ត<br>Statement of Practice Standard | វិសាលភាពនៃសមត្ថភាពអនុវត្តការងារ<br>Scope of Performing Abilities |
|---|---|
| | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវសហការណ៍ជាមួយអ្នកសើបអង្កេតផ្លូវការ ឬក្រៅផ្លូវការ ដោយផ្តល់ព័ត៌មានពិតប្រាកដ ពេញលេញ<br>Dental practitioners should co-operate with any relevant formal or informal inquiry and give full and truthful information |
| 4. ត្រូវតែមានដំណើរការធានាគុណភាព ក្នុងការតាមដានបទដ្ឋានពិនិត្យ ព្យាបាលជំងឺ ដោយអ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យ រាប់បញ្ចូលទាំងភាពសមស្រប ភាពចាំបាច់ និងគុណភាពនៃការពិនិត្យ ព្យាបាលជំងឺ ។ ត្រូវតែមានយន្តការដើម្បី កំណត់និងដោះស្រាយភាពខ្វះខាតនៃការពិនិត្យ ព្យាបាលជំងឺ នៅពេលសមស្រប។<br><br>There must be quality assurance processes in place to monitor standards of care provided by dental practitioners, including appropriateness, necessity and quality of care. There must be mechanisms to identify and address deficiencies of care, where appropriate. | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវយល់ដឹងពីគោលការណ៍វិទ្យាសាស្ត្រ និងអនុវត្តចំណេះដឹងផ្នែកជីវៈសាស្ត្រ ជីវៈវេជ្ជសាស្ត្រ អាកប្បកិរិយា និងបច្ចេកទេសវិទ្យាសាស្ត្រនៃការពិនិត្យ ព្យាបាល ក្នុងការគ្រប់គ្រងអ្នកជំងឺ<br>Dental practitioners should understand scientific principles and apply the knowledge of biological, biomedical, behavioural, technical and clinical sciences in the management of patients<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវថែរក្សា និងកត់ត្រាទុកពីប្រវត្តិអ្នកជំងឺ ដែលបានរៀបរាប់តាមការសាកសួរ ឲ្យបានល្អ<br>Dental practitioners should obtain, record and interpret a comprehensive and contemporaneous patient history<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវប្រកាន់យកគោលការណ៍រួម និងការពារ ការព្យាបាលជំងឺ ហើយត្រូវបង្កើតផែនការអនុវត្តន៍ក្នុងការព្យាបាលជំងឺ<br>Dental practitioners should adopt a holistic and preventive approach to patient care, and establish an individualised treatment plan<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវប្រត្តិបត្តការងារទៅតាមចំណេះដឹង ជំនាញនិងសមត្ថភាពរបស់ខ្លួន<br>Dental practitioners should work within their knowledge, skills, abilities and competence<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវទទួលស្គាល់ការព្យាបាលដែលមិនមែនជាជំនាញ និងបទពិសោធន៍របស់ខ្លួន ហើយបើចាំបាច់ត្រូវបញ្ជូនបន្តទៅអ្នកមានជំនាញ ដែលមានបទពិសោទធន៍<br>Dental practitioners should recognise the treatments that are beyond their skills and experience, and refer appropriately |

| បទដ្ឋាននៃការអនុវត្ត<br>Statement of Practice Standard | វិសាលភាពនៃសមត្ថភាពអនុវត្តការងារ<br>Scope of Performing Abilities |
|---|---|
| | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ដែលបានទទួលស្នងភារកិច្ច ត្រូវប្រត្តិបត្តឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងគណនេយ្យភាព<br>Dental practitioners who delegate tasks must do so appropriately and effectively, and maintain accountability |
| 5. ចាំបាច់ត្រូវតែមានការពិនិត្យសុខភាព និង ដំណើរការគ្រប់គ្រង សម្រាប់អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ប្រកបដោយប្រសិទ្ធភាព ប្រសិនបើមានការចាំបាច់<br><br>There must be in place effective health screening and management processes for dental practitioners, where necessary. | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវការពារអ្នកជំងឺ និងមិត្តរួមការងារ ពីហានិភ័យដែលកើតឡើងដោយថាហេតុពីសុខភាព និងការប្រត្តិបត្តការងាររបស់ខ្លួន<br>Dental practitioners should safeguard patients and colleagues from risks arising from their health, conduct or performance<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវបញ្ឈប់ការធ្វើពោគវិនិច្ឆ័យខ្លួនឯង ការវាយតម្លៃខ្លួនឯង និងការប្រើថ្នាំខ្លួនឯង<br>Dental practitioners should refrain from self-diagnosis, self-assessment and self-medication<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវស្វែងរកជំនួយឲ្យបានទាន់ពេលវេលា ហើយផ្តល់ពត៍មានដល់អជ្ញាធរបញ្ញត្តិកម្មវិជ្ជាជីវៈ ប្រសិនបើមានឱនភាព ឬពិការភាព( រួមទាំងការរំលោភបំពានសារធាតុញៀន ឬការញៀន ) ដែលអាចប៉ះពាល់ដល់ការងាររបស់ពួកគាត់<br>Dental practitioners should seek help promptly and inform their Professional Regulatory Authority if there is an impairment or disability (including substance abuse or addiction) that may affect their work<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវចាត់វិធានការសមស្រប ប្រសិនបើពួកគេសង្ស័យថាមានការរំលោភបំពានចំពោះកុមារ ឬអ្នកជំងឺដែលងាយរងគ្រោះ<br>Dental practitioners should take appropriate action if they suspect possible abuse of children or vulnerable adult patients<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវលើកទឹកចិត្តឲ្យមានវប្បធម៌មួយ ដែលបុគ្គលិកអាចនិយាយពីការព្រួយបារម្ភរបស់ពួកគេដោយបើកចំហ និងគ្មានការភ័យខ្លាចពីការសងសឹក<br>Dental practitioners should encourage a culture where staff can voice their concerns openly, and without fear of reprisal |

| បទដ្ឋាននៃការអនុវត្ត<br>**Statement of Practice Standard** | វិសាលភាពនៃសមត្ថភាពអនុវត្តការងារ<br>**Scope of Performing Abilities** |
|---|---|
| 6. ត្រូវតែមានដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់ អំពីបញ្ហាសុខភាព និងសុវត្ថិភាព (រួមទាំងសុវត្ថិភាពវិទ្យុសកម្ម) ការគ្រប់គ្រងផ្នែកសង្គ្រោះបន្ទាន់ បណ្តឹងរបស់អ្នកជំងឺ និងការរក្សាព័ត៌មានសម្ងាត់របស់អ្នកជំងឺ<br><br>There must be in place effective processes addressing areas of occupational health and safety (including radiation safety), management of medical emergencies, patient complaints, and confidentiality of patient information | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវអនុវត្តតាមគោលការណ៍ណែនាំ ស្តីអំពីសុវត្ថិភាពវិទ្យុសកម្ម ការចម្លងរោគ និងព្យាបាលអ្នកជំងឺនៅកន្លែងដែលមានអនាម័យ និងសុវត្ថិភាព<br>Dental practitioners should follow guidelines regarding radiation safety and infection control, and treat patients in a hygienic and safe working environment<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវធ្វើកំណត់ត្រាប្រវត្តិអ្នកជំងឺឲ្យបានត្រឹមត្រូវ ច្បាស់លាស់ និងរក្សាទុក ឲ្យបានល្អ<br>Dental practitioners should make and keep contemporaneous, complete, clear, legible and accurate patient records<br><br>• កំណត់ត្រាប្រវត្តិអ្នកជំងឺ ដែលបញ្ជូនទៅអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ឬអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ត្រូវតែបញ្ជាក់ក្នុងកំណត់ត្រាប្រវត្តិអ្នកជំងឺឲ្យបានត្រឹមត្រូវ<br>An accurate record of referrals of patients to another dental professional or other health professional must be made in the patient's notes<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវរក្សាការសំងាត់នូវព័ត៌មានរបស់អ្នកជំងឺ និងប្រើប្រាស់ក្នុងគោលបំណងពិនិត្យព្យាលពួកគាត់តែប៉ុណ្ណោះ<br>Dental practitioners should protect the confidentiality of patients' information and only use it for the purpose for which it was given<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និងធានារក្សាការសំងាត់នូវព័ត៌មានរបស់អ្នកជំងឺគ្រប់កាលៈទេសៈ<br>Dental practitioners should be competent in the use of information technology, and ensure patient information is protected at all times<br><br>• អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវមានការរៀបចំឱ្យបានសមស្របសម្រាប់អ្នកជំងឺ ដើម្បីស្វែងរកសំណង ប្រសិនបើពួកគាត់ទទួលរងគ្រោះថ្នាក់ដោយសាការប្រើប្រាស់សេវា<br>Dental practitioners should have appropriate arrangements in place for patients to seek compensation if they suffer harm |

| បទដ្ឋាននៃការអនុវត្ត<br>Statement of Practice Standard | វិសាលភាពនៃសមត្ថភាពអនុវត្តការងារ<br>Scope of Performing Abilities |
|---|---|
| | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវធ្វើឲ្យប្រាកដថា មានដំណើរការដាក់ពាក្យបណ្តឹងមួយ ដែលមានប្រសិទ្ធិភាព សម្រាប់អ្នកជំងឺ<br>Dental practitioners should make sure that there is an effective complaints process always available for patients |
| 7. ត្រូវតែមានប្រព័ន្ធកែលម្អគុណភាពទាំងខាងក្នុងនិងខាងក្រៅ ប្រកបដោយប្រសិទ្ធភាព (រួមទាំងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការ វាយតម្លៃការងាររបស់បុគ្គលិក) ដើម្បីធានាឱ្យបានគ្រប់គ្រាន់នៃការផ្តល់សេវាកម្ម ការកែ លម្អគុណភាព និងការផ្សារភ្ជាប់ទៅនឹង ការអនុវត្តន៍នាពេលបច្ចុប្បន្ន។<br><br>There must be in place effective internal and external quality improvement processes (incl. staff professional development and performance evaluation) to ensure adequacy of service delivery, quality improvement and linkage to contemporary practice | • អ្នកប្រកបវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវធ្វើការវាយតម្លៃ និងធ្វើការសិក្សាដោយខ្លួនឯង អភិវឌ្ឍន៍ជំនាំញវិជ្ជាជីវៈ ដើម្បីរក្សាសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន<br>Dental practitioners should engage in self-assessment, critical thinking, and self-directed learning to maintain clinical competence<br><br>• អ្នកវិជ្ជាជីវៈទន្តសាស្ត្រទាំងអស់ ត្រូវផ្តល់សេវាពិនិត្យ និងព្យាបាល ប្រកបដោយគុណភាព ផ្អែកលើស្ថានភាពជំងឺជាក់ស្តែង ស្របតាមបទដ្ឋាបគត្តិយុត្ត<br>Dental professionals should provide good quality care based on current evidence and authoritative guidance<br><br>• អ្នកមានវិជ្ជាជីវៈជាទន្តពេទ្យទាំងអស់ ត្រូវធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ស្របតាមជំនាញពេញមួយជីវិតការងាររបស់ខ្លួន<br>Dental practitioners should update and develop their professional knowledge and skills throughout their working life |

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១៨

**ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**